ក្រសួងមុខងារសាធារណៈ

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈសម្រាប់ឆ្នាំ២០១៦ និងទិសដៅការងារអាទិភាពបន្ត

បទបង្ហាញ៖ ឯកឧត្តម គង់ សុភី អគ្គនាយកគោលនយោបាយមុខងារសាធារណៈក្រសួងមុខងារសាធារណៈ
និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# មាតិកា

១. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

២. បញ្ហាប្រឈម

៣. ទិសដៅការងារអាទិភាព

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨



# ១. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

# វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិឆ្នាំ២០១៦

ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ក្នុងឆ្នាំ២០១៦ ដោយផ្តោតទៅ លើការកែលម្អគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស មានវឌ្ឍនភាពការងារជាវិជ្ជមានមួយចំនួនគួរឱ្យកត់សម្គាល់ ក្នុងនោះមានដូចជា៖

| សកម្មភាពការងារ | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | |
|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
| ការកែលម្អគុណភាពសេវាសាធារណៈ | ១៣ | ១ | ១២ | ០ |
| ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស | ១៦ | ០ | ១៤ | ២ |
| ការកែទម្រង់ប្រព័ន្ធបៀវត្ស | ៦ | ៤ | ២ | ០ |
| សរុប | ៣៥ | ៥ | ២៨ | ២ |

# ការកែលម្អសេវាសាធារណៈ-លទ្ធផលសង្ខេបសំខាន់ៗ

| ចង្កោមសកម្មភាព | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | |
|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត |
| ចង្កោមសកម្មភាពទី១ | ៣ | ០ | ៣ | ០ |
| ចង្កោមសកម្មភាពទី២ | ១ | ០ | ១ | ០ |
| ចង្កោមសកម្មភាពទី៣ | ២ | ០ | ២ | ០ |
| ចង្កោមសកម្មភាពទី៤ | បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ | | | |
| ចង្កោមសកម្មភាពទី៥ | ២ | ០ | ២ | ០ |
| ចង្កោមសកម្មភាពទី៦ | ២ | ០ | ២ | ០ |
| ចង្កោមសកម្មភាពទី៧ | ៣ | ១ | ២ | ០ |
| សរុប | ១៣ | ១ | ១២ | ០ |

# ការកែលម្អសេវាសាធារណៈ-លទ្ធផលសង្ខេបសំខាន់។

1. បានអនុវត្តក្នុងការធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាធារណៈ មានក្រសួង ស្ថាប័នចំនួនអង្គភាពផ្តល់សេវាចំនួន ២៦ បានធ្វើកម្រងព័ត៌មានសេវាសាធារណៈ ដែលបានធ្វើបច្ចុប្បន្នកម្មមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
2. បានកំណត់សេវា អាទិភាពពី០៣ ទៅ០៥សេវា ដែលផ្តល់ដោយក្រសួង ស្ថាប័ន បានចំនួន ១២ ក្រសួង ស្ថាប័ន
3. បានរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន (Mobile App for Cambodia Public Service)
4. បាននឹងកំពុងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ
5. បាននឹងកំពុងសហការជាមួយលេខាធិការដ្ឋានអាស៊ានដើម្បីអនុវត្តគម្រោងក្នុងការបង្កើតឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈសម្រាប់ប្រទេស អាស៊ានទាំង១០





# ការកែលម្អសេវាសាធារណៈ-លទ្ធផលសង្ខេបសំខាន់។

5. បានចុះត្រួតពិនិត្យ និងផ្តល់អនុសាសន៍កែលម្អនីតិវិធីនិងយន្តការក្នុងការផ្តល់សេវាស ធារណៈ របស់ក្រសួង សាធារណការ និងដឹកជញ្ជូន ក្រសួងយុត្តិធម៌ ក្រសួងរៀបចំ ដែនដី នគរូបនីយកម្មនិងសំណង់ និងក្រសួងពាណិជ្ជកម្ម ដោយផ្អែកលើសូចនាករ ចំនួន ០៩
6. បានពិនិត្យមើល និងរៀបចំដាក់ឱ្យដំណើរការយន្តការក្នុងផ្តល់ព័ត៌មានត្រឡប់ និង បណ្តឹងតវ៉ាដល់ក្រសួងចំនួន១៧
7. បានចុះពិនិត្យ និងផ្តល់ការឯកភាពលើការដាក់ឱ្យដំណើរការយន្តការទីភ្នាក់ងារ ប្រតិបត្តិការពិសេសបន្ថែមទៀតនៅមន្ទីរពេទ្យបង្អែកខេត្តចំនួន០៤ គឺ ខេត្តព្រៃវែង ខេត្តកំពត ខេត្តក្រចេះ និងខេត្តកំពង់ធំ
8. បានធ្វើទស្សនកិច្ចសិក្សា និងដកស្រង់បទពិសោធន៍ល្អពីប្រទេសឥណ្ឌូនេស៊ី និងព្រះ រាជាណាចក្រថៃឡង់អំពីការផ្តល់សេវាសាធារណៈ





# ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស-លទ្ធផលសង្ខេបសំខាន់ៗ

| ចង្កោមសកម្មភាព | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត | |
| ចង្កោមសកម្មភាពទី១ | ៥ | ០ | ៣ | ២ | |
| ចង្កោមសកម្មភាពទី២ | ៤ | ០ | ៤ | ០ | សកម្មភាពទី១និងទី២បន្តពីឆ្នាំ២០១៥ |
| ចង្កោមសកម្មភាពទី៣ | ៣ | ០ | ៣ | ០ | សកម្មភាពទី១និងទី២បន្តពីឆ្នាំ២០១៥ |
| ចង្កោមសកម្មភាពទី៤ | បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ | | | | |
| ចង្កោមសកម្មភាពទី៥ | បានបញ្ចប់នៅក្នុងឆ្នាំ២០១៥ រួចរាល់ហើយ | | | | |
| ចង្កោមសកម្មភាពទី៦ | ២ | ០ | ២ | ០ | |
| ចង្កោមសកម្មភាពទី៧ | ១ | ០ | ១ | ០ | |
| ចង្កោមសកម្មភាពទី៨ | ១ | ០ | ១ | ០ | |
| សរុប | ១៦ | ០ | ១៤ | ២ | |

# ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស-លទ្ធផលសង្ខេបសំខាន់ៗ

1. បានដាក់ចេញរបាយការណ៍ស្តីពីការសិក្សា និងវិភាគអំពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីបំពេញការងាររបស់នាយកដ្ឋានបុគ្គលិក របស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងអង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ
2. បានដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យវត្តមានបំពេញការងាររបស់មន្ត្រីរាជការ
3. បានកែសម្រួល និងដាក់ឱ្យអនុវត្តការពន្លឿននីតិវិធីក្នុងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
4. បានធ្វើការកំណត់ចំនួនមុខតំណែង សម្រាប់មុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
5. បានរៀបចំដាក់ចេញសេចក្តីព្រាងស្តីពីអង្គរដ្ឋបាល និងរៀបចំការពិពណ៌នាមុខតំណែងសម្រាប់គ្រប់មុខតំណែងទាំងអស់ក្នុងមុខងារសាធារណៈ
6. បានបញ្ចប់ការរៀបចំឯកសារប្រព័ន្ធគ្រប់គ្រងគុណផល (PMS)
7. បានរៀបចំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំការពិពណ៌នាមុខតំណែង

# ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស-សកម្មភាពដែលមិនទាន់បានអនុវត្ត

1. រៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និងប្រវត្តិសមត្ថភាពការងារ ដោយមានយន្តការគ្រប់គ្រង និងវាយតម្លៃសម្រាប់ធ្វើផែនការអាជីពស្របតាមសេចក្តីត្រូវការ
2. សិក្សារៀបចំបង្កើតវិទ្យាស្ថានរដ្ឋបាលសាធារណៈដើម្បីផ្តល់ការស្រាវជ្រាវផ្នែកគោលនយោបាយ ការបណ្តុះបណ្តាលពាក់ព័ន្ធមុខងារសាធារណៈ

# ការកែទម្រង់ប្រព័ន្ធបៀវត្ស-លទ្ធផលសង្ខេបសំខាន់ៗ

| ចង្កោមសកម្មភាព | ចំនួនសកម្មភាព | វឌ្ឍនភាពការងារ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | សកម្មភាពដែលសម្រេចបានពេញលេញ | សកម្មភាពដែលសម្រេចបានដោយផ្នែក | សកម្មភាពដែលមិនទាន់បានអនុវត្ត | |
| ចង្កោមសកម្មភាពទី១ | ២ | ១ | ១ | ០ | |
| ចង្កោមសកម្មភាពទី២ | ២ | ២ | ០ | ០ | |
| ចង្កោមសកម្មភាពទី៣ | ១ | ០ | ១ | ០ | |
| ចង្កោមសកម្មភាពទី៤ | ១ | ១ | ០ | ០ | |
| ចង្កោមសកម្មភាពទី៥ | បានអនុវត្តរួចរាល់នៅឆ្នាំ២០១៥ | | | | |
| សរុប | ៦ | ៤ | ២ | ០ | |

# ការកែទម្រង់ប្រព័ន្ធបៀវត្ស-លទ្ធផលសង្ខេបសំខាន់ៗ

| ល.រ | ប្រភេទមន្ត្រីរាជការ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ |
|---|---|---|---|
| ១ | វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស | ៥៥២,៨០០ រៀល | ៧០០,៥០០ រៀល |
| ២ | វិស័យអប់រំ | ៦៥២,៨០០ រៀល | ៨០០,៥០០ រៀល |
| ៣ | វិស័យសុខាភិបាល | ៦៥២,៨០០ រៀល | ៨០០,៥០០ រៀល |
| ៤ | នគរបាលជាតិ | ៦២៨,២៧០ រៀល | ៧៨៤,៧៣០ រៀល |
| ៥ | យោធិន | ៥៨២,៤៣០ រៀល | ៧៣៣,៧៣០ រៀល |

# ការកែទម្រង់ប្រព័ន្ធបៀវត្ស-លទ្ធផលសង្ខេបសំខាន់ៗ

| ល.រ | ប្រភេទមន្ត្រីរាជការ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ |
|---|---|---|---|
| ៦ | មន្ត្រីជាប់កិច្ចសន្យា | ១៦០,000 រៀល | ៤00,000 រៀល |
| ៧ | ក្រុមប្រឹក្សារាជធានី ខេត្ត | ៨00,000 រៀល | ៨៧0,000 រៀល |
| ៨ | ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ៥00,000 រៀល | ៦៥0,000 រៀល |
| ៩ | ក្រុមប្រឹក្សា ឃុំ សង្កាត់ | ៣00,000 រៀល | ៤៨0,000 រៀល |
| ១០ | មេភូមិ | ១៦០,000 រៀល | ២00,000 រៀល |
| ១១ | អនុប្រធានភូមិ | ១៤០,000 រៀល | ១៦០,000 រៀល |
| ១២ | សមាជិកភូមិ | ១២០,000 រៀល | ១៤០,000 រៀល |

# ការកែទម្រង់ប្រព័ន្ធបៀវត្ស-លទ្ធផលសង្ខេបសំខាន់ៗ

1. បានរៀបចំ និងដាក់ឱ្យអនុវត្តការបញ្ជូន និងទទួលទិន្នន័យបៀវត្សមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធអេឡិចត្រូនិច
2. បានរៀបចំបង្កើតកម្មវិធី និងតារាងបៀវត្សមន្ត្រីជាប់កិច្ចសន្យាទៅក្នុងប្រព័ន្ធទិន្នន័យរួមមន្ត្រីរាជការស៊ីវិល
3. បានរៀបចំដាក់ឱ្យអនុវត្តការបើកបៀវត្សមន្ត្រីជាប់កិច្ចសន្យាទៅតាមប្រព័ន្ធធនាគារ
4. បានរៀបចំកែសម្រួលប្រាក់បំណាច់មុខងាររបស់នគរបាលជាតិ និងយោធិនឱ្យមានសង្គតិភាពទៅនឹងប្រាក់បំណាច់ មុខងារមន្ត្រីរាជការស៊ីវិល
5. បានរៀបចំកំណត់ឡើងវិញនូវប្រាក់ម៉ោងបន្ថែមសម្រាប់វិស័យអប់រំ និងប្រាក់វេនយាមសម្រាប់វិស័យសុខាភិបាល
6. បានបញ្ជូនក្រុមការងារអន្តរក្រសួង (ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងសុខាភិបាល) ទៅសិក្សាស្វែងយល់ពីប្រព័ន្ធបៀវត្សរបស់ប្រទេសជប៉ុន នៅប្រទេសជប៉ុនរយៈពេល១០ថ្ងៃ ដើម្បីជាធាតុចូលនៅក្នុងការរៀបចំគោលនយោបាយបៀវត្សនាពេលខាងមុខ

# ការកែទម្រង់ប្រព័ន្ធបៀវត្ស-លទ្ធផលសង្ខេបសំខាន់។

7. បានរៀបចំដំឡើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីរាជការបំពេញភារកិច្ចក្រៅប្រទេសនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
8. បានរៀបចំដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារនិងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល

# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

បានដាក់ចេញនូវឯកសារពាក់ព័ន្ធទៅនឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ រួមមាន៖

1. របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥ និងឆ្នាំ២០១៦
2. ឯកសារគោលការណ៍ណែនាំស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ (M&E Guideline)
3. បានរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
4. បានរៀបចំសិក្ខាសាលាស្តីពីការជំរុញ និងការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិទូទាំងប្រទេសចំនួន០៦លើក កម្រិតថ្នាក់ជាតិ ០១លើក និងថ្នាក់តំបន់ចំនួន ០៥លើក **សរុប មន្ត្រីចូលរួមមានចំនួន ១៧៤៦ រូប ក្នុងនោះ ស្ត្រី ២១៧ រូប**
5. បានបណ្តុះបណ្តាលដល់មន្ត្រីកម្រិតគ្រប់គ្រងនៃក្រសួងមុខងារសាធារណៈ ក្នុងនោះរួមមាន៖ អគ្គាធិការរង អធិការ អនុប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ប្រធានការិយាល័យ សរុប ៦០ រូប ដោយផ្តោតសំខាន់ទៅលើប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

# ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ

1. ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋានកំណែទម្រង់ទាំង៣ លេខាធិការដ្ឋានទាំង៣បានឯកភាពគ្នាបង្កើតនូវផែនការសកម្មភាព ដែលត្រូវអនុវត្តរួមគ្នា មានដូចខាងក្រោម៖
   - ពង្រឹងការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់លាភការផ្សេងៗតាមប្រព័ន្ធធនាគារ ឬតាមប្រព័ន្ធ E-transfer (លេខាធិការដ្ឋាន គ.ក.រ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត)
   - រៀបចំក្របខណ្ឌនិងយន្តការអនុវត្តទណ្ឌកម្មចំពោះការគ្រប់គ្រងធនធានសាធារណៈ (ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត)
   - កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យមានសង្គតិភាពជាមួយនឹងប្រព័ន្ធដំណើការការងារថ្មីដែលរួមមាន ផ្នែករដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (អគ្គលេខាធិការដ្ឋាន អ គ ហ ជាអ្នកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ ក រ និងលេខាធិការដ្ឋាន គ ជ អ ប ជាអ្នកទទួលបន្ទុកផ្នែករដ្ឋបាល បុគ្គលិក និងបច្ចេកទេស)

# ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ

- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធអធិការកិច្ច សវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួងស្ថាប័នដើម្បីធានាបាននូវសុខដុមនីយកម្ម (ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត)
- បង្កើនគុណភាពលើការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សាលាភូមិន្ទរដ្ឋបាល ជាអ្នកដឹកនាំសម្របសម្រួលអនុវត្ត)
- រៀបចំក្របខណ្ឌរួមនៃការគ្រប់គ្រង និងការបែងចែកប្រាក់រង្វាន់ពីចំណូលមិនមែនសារពើពន្ធប្រកបដោយសមធម៌ និងប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (អគ្គលេខាធិការដ្ឋាន អ គ ហ ជាអ្នកដឹកនាំ និងសម្របសម្រួលអនុវត្ត)

# ការផ្សារភ្ជាប់ការងារកែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ

2. បានសម្របសម្រួល និងពង្រឹងកិច្ចសហប្រត្តិការជាមួយដៃគូអភិវឌ្ឍ ក្នុងនោះរួមមាន World Bank, ADB, Japan-Jica, Korea-Koica, GIZ ដើម្បីជួយគាំទ្រដល់ការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ

3. បានរៀបចំសំណើគម្រោងស្តីពីជំនួយបច្ចេកទេសដាក់ជូនភាគីអាល្លឺម៉ង់សម្រាប់ការគាំទ្រនៅឆ្នាំ ២០១៩-២០២៣

4. បានពិភាក្សាជាមួយធនាគារពិភពលោក (World Bank) ស្តីពីជំនួយបច្ចេកទេសពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) និងសេវាសាធារណៈ (Service Delivery)

# ២. បញ្ហាប្រឈមក្នុងការអនុវត្តការងារ កែទម្រង់រដ្ឋបាលសាធារណៈ

# បញ្ហាប្រឈមក្នុងការអនុវត្ត

- ភាពជាម្ចាស់របស់ក្រសួងស្ថាប័ននៅមានកម្រិតក្នុងការដឹកនាំ សម្របសម្រួល និងអនុវត្ត
- សមត្ថភាពក្នុងការគ្រប់គ្រងការងារមិនបានក្លាយជាប្រព័ន្ធការងារ
- កម្រិតការងារអាទិភាពមានច្រើននៅក្នុងការអនុវត្តដែលពិបាកនឹងសម្រេចបានតាមការគ្រោងទុក
- កម្លាំងធនធានមនុស្សមិនបានប្រមូលផ្តុំ គឺស្ថិតនៅរាយប៉ាយដែលធ្វើឱ្យផលិតភាព ប្រសិទ្ធភាពនៃការអនុវត្តការងារនៅមានកម្រិត
- ថវិកាដែលត្រូវអនុវត្ត គឺមាននីតិវិធីច្រើន ស្មុគស្មាញ ដែលធ្វើឱ្យការទម្លាក់និងផ្តល់ថវិកាសម្រាប់ការអនុវត្តមិនបានទាន់ពេលវេលា

# ៣. ទិសដៅការងារអាទិភាព

# ទិសដៅការងារអាទិភាព

- **ការកែលម្អគុណភាពសេវាសាធារណៈ**
  1. ត្រួតពិនិត្យ និងកែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសាធារណរបស់ក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ
  2. រៀបចំបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាសាធារណៈ ដោយមានការឯកភាពគ្នារវាងក្រសួងមុខងារសាធារណៈ និងក្រសួងសាមី(មួយក្រសួងម្តង)
  3. រៀបចំបង្កើត និងដាក់ឱ្យអនុវត្ត Call Centre
  4. រៀបចំ និងដាក់ឱ្យអនុវត្តច្រកទ្វារអេឡិកត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)
  5. រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីសេវាសាធារណៈ
  6. រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃស្ថាប័នរដ្ឋ និងការផ្តល់ពានរង្វាន់ និងប្រាក់រង្វាន់ដល់ក្រសួងស្ថាប័នសាធារណៈដែលមានស្នាដៃល្អ

# ទិសដៅការងារអាទិភាព

➢ **ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស**

1. រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
2. ពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ មធ្យម និងមន្ត្រីក្របខណ្ឌថ្មី
3. ជំរុញការអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
4. រៀបចំព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ
5. រៀបចំអង្គមន្ត្រីរាជការស៊ីវិល និងមុខតំណែងវិជ្ជាជីវៈ
6. រៀបចំការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈក្នុងរចនាសម្ព័ន្ធគ្រប់គ្រង
7. រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្ត

# ទិសដៅការងារអាទិភាព

## ➢ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

8. ត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា
9. រៀបចំការពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
10. រៀបចំបង្កើតមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងសមត្ថភាពជំនាញរបស់មន្ត្រីរាជការស៊ីវិល និងប្រវត្តិសមត្ថភាពការងារ
11. រៀបចំអភិវឌ្ឍ និងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
12. ជំរុញការអនុវត្តសារាចរណែនាំ ស្តីពីបែបបទនីតិវិធី អនុវត្តព្រះរាជក្រឹត្យលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

# ទិសដៅការងារអាទិភាព

## ➢ ការកែទម្រង់ប្រព័ន្ធបៀវត្ស

- រៀបចំដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់រាជរដ្ឋាភិបាល
- សិក្សា និងរៀបចំគោលនយោបាយបៀវត្ស ២០១៩-២០២៣
- រៀបចំបង្កើតកម្មវិធី និងដាក់ឱ្យដំណើរការកាត់ពន្ធបៀវត្សរបស់ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នឯករាជ្យ

# ទិសដៅការងារអាទិភាព

- **ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ**
  - រៀបចំត្រួតពិនិត្យមើលលើវឌ្ឍភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ
  - ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្ត រួមមាន (១)ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (២)ការរៀបចំការពិពណ៌នាមុខតំណែង (៣)ការពង្រឹងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
  - ចុះតាមដាន និងត្រួតពិនិត្យចំនួនមន្ត្រីរាជការក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សូមអរគុណ!